**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Feb-2014, 11:40
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ
ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**
ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម៖ **បារាំង**
កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**
ប្រភេទនៃចំណាត់ថ្នាក់៖
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖
ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖
ហត្ថលេខា៖

---

**សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ស្ដីពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមស្ថាពរនៃសំណុំរឿង ០០២/០១ មុននឹងចាប់ផ្ដើមសំណុំរឿង ០០២/០២**

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**
មេធាវី គង់ សំអុន
មេធាវី Anta GUISSÉ
មេធាវី Arthur VERCKEN

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ូរ ឧត្ដារ
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

កញ្ញា អ៊ូច ស្រីផាត់

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្តីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានផ្ញើជូនភាគីនូវផែនការការងាររបស់ខ្លួន សម្រាប់សំណុំរឿង ០០២ វគ្គទី ២ (០០២/០២)[1] ដោយស្នើឲ្យមេធាវីការពារក្ដីលោក ខៀវ សំផន ("មេធាវីការពារក្ដី") ដាក់ត្រឹមថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ នូវសេចក្ដីសន្និដ្ឋានពាក់ព័ន្ធទៅនឹង *"ទស្សនៈរបស់ខ្លួនថា សំណុំរឿង ០០២/០១ គួរតែត្រូវបានសម្រេចជាស្ថាពរសិន ដោយរួមទាំងដំណើរការនីតិវិធីប្ដឹងសាទុក្ខ ប្រសិនបើមាន មុននឹងចាប់ផ្ដើមសវនាការដេញដោលលើភ័ស្តុតាង នៅក្នុងសំណុំរឿង ០០២/០២"*[2] ។

២. បញ្ហាជាប់ពាក់ព័ន្ធគ្នានៃការជំនុំជម្រះក្ដីដែលត្រូវបានបំបែកជាវគ្គតូចៗ បានចោទឡើង តាំងពីមានការបំបែកសំណុំរឿង ០០២ (ផ្នែកទី I)។ មេធាវីការពារក្ដី យល់ឃើញថា ការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ តម្រូវឲ្យជំនុំជម្រះសំណុំរឿង ០០២ វគ្គទី ១ (០០២/០១) ចប់ជាស្ថាពរសិន មុននឹងចាប់ផ្ដើមសំណុំរឿងវគ្គបន្ទាប់ទៀត (០០២/០២) (ផ្នែកទី II)។ ម្យ៉ាងវិញ ទៀត សេចក្ដីសម្រេចនានាដែលអាចត្រូវបានប្ដឹងសាទុក្ខ ក្នុងពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្ដីនៃសំណុំរឿង ០០២/០១ ត្រូវដោះស្រាយឲ្យចប់រួចរាល់សិន មុននឹងចាប់ផ្ដើមសំណុំរឿង ០០២/០២ ដោយមានចៅក្រមជំនុំជម្រះដដែល (ផ្នែកទី III)។ ជាចុងក្រោយ បញ្ហាពេលវេលាចាំបាច់សម្រាប់នីតិវិធីបណ្ដឹងសាទុក្ខ មិនអាចឲ្យចេញសេចក្ដីសម្រេចចាប់ផ្ដើមសំណុំរឿង ០០២/០២ មុនពេលឆ្លងកាត់ជំហានទាំងអស់នេះនោះទេ (ផ្នែកទី IV)។

## I- ប្រវត្តិនីតិវិធី (ត្រួសៗ)

៣. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះ បានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២ ដោយបញ្ជាក់ថា *"បទចោទប្រកាន់ទាំងអស់ (...) ត្រូវទុកដើម្បីលើក*

[1] ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់សំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ, អនុស្សរណៈ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **E301/5** ("ផែនការការងារ **E301/5**")។

[2] ផែនការការងារ **E301/5** កថាខណ្ឌ ៧។

*យកទៅដេញដោលនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីក្រោយៗទៀត នៅក្នុងសំណុំរឿង ០០២* ។ ក្នុងពេលជាមួយគ្នានោះ អង្គជំនុំជម្រះ បានប្រកាសថា *"ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការជំនុំជម្រះនៅដំណាក់កាលបន្ទាប់ លើសំណុំរឿង ០០២ នឹងផ្ដល់ជូនដល់ភាគី និងសាធារណជន ឲ្យបានជ្រាបនាពេលសមស្របខាងមុខ"*[3]។

៤. នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញា បានស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញ ពីដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ និងបានស្នើសុំពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១។ សហព្រះរាជអាជ្ញាបានលើកឡើង ជាអាទិ៍ថា៖

> *"ភាពយឺតយ៉ាវប្រហែលជាអាចកើតមានឡើង ដោយសារបញ្ហាពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានទទួលយក និងអាជ្ញាអស់ជំនុំ នៅចន្លោះការបើកការជំនុំជម្រះវគ្គទី ១ និងវគ្គទី ២។ តាមផ្លូវច្បាប់ ទំនងជាមិនអាចទៅរួចទេ ក្នុងការពន្លឿនការជំនុំជម្រះវគ្គបន្តបន្ទាប់ ដោយផ្អែកលើតួនាទីរបស់ជនជាប់ចោទ ដូចបានរកឃើញ នៅក្នុងការជំនុំជម្រះវគ្គទី ១ (...)។ យន្តការគតិយុត្តិពីរ ដែលតាមរយៈនោះ អង្គជំនុំជម្រះអាចរួសរាន់ពិចារណាលើបញ្ហាដែលបានពិនិត្យមើល នៅក្នុងការជំនុំជម្រះវគ្គទី ១ គឺសច្ចទស្សន៍តុលាការលើអង្គហេតុដែលបានទទួលយក និងអាជ្ញាអស់ជំនុំ។ អង្គជំនុំជម្រះមិនអាចផ្អែកលើគោលការណ៍ណាមួយ ក្នុងចំណោមគោលការណ៍ទាំងពីរ ជាមូលដ្ឋានសម្រាប់ការជំនុំជម្រះវគ្គទី ២ បានទេ ប្រសិនបើបណ្ដឹងសាទុក្ខជាយថាហេតុប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០១ មិនទាន់ត្រូវបានដោះស្រាយចប់រួចរាល់នោះ។ ដោយសារតែវ័យចាស់ជរារបស់ជនជាប់ចោទ ភាពយឺតយ៉ាវបែបនេះធ្វើឲ្យការជំនុំជម្រះវគ្គទី ២ មិនអាចប្រព្រឹត្តទៅបានទេ"*[4]។

៥. នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានស្នើសុំ

---

[3] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **E124** កថាខណ្ឌ ៧ និងផ្នែកសម្រេចសេចក្ដី។

[4] សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពី "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/2** កថាខណ្ឌ ២៤ និងកថាខណ្ឌ ២៦-២៨។

ឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញ នូវដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដោយចង្អុលបង្ហាញថា៖

*"ដូចគ្នានឹងសហព្រះរាជអាជ្ញាដែរ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញថា វាដូចជាមិនទំនងនោះទេ ដែលសវនាការតូចៗនឹងប្រព្រឹត្តទៅជាបន្តបន្ទាប់ ទៅតាមបទចោទនៃអង្គហេតុជាក់លាក់នានានោះ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានការព្រួយបារម្ភអំពីលទ្ធភាពនៃសេណារីយ៉ូនេះ ដោយសវនាការតូចៗជាច្រើនអាចនឹងប្រព្រឹត្តទៅជាបន្តបន្ទាប់ យោងលើសភាពស្មុគស្មាញនៃសំណុំរឿង ជរាភាពរបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងបញ្ហានីតិវិធី និងបញ្ហាផ្លូវច្បាប់ស្មុគស្មាញសំខាន់ៗនានា ដែលនឹងលេចឡើង តាមរយៈដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដូចជា អាជ្ញាអស់ជំនុំ ជាដើម"*[5]។

៦. នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះ បានបដិសេធសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញ ដោយបានបញ្ជាក់ថា៖

*"ដីកាបំបែកសំណុំរឿងពាក់ព័ន្ធតែទៅនឹងលំដាប់លំដោយនៃការជំនុំជម្រះ នៅក្នុងសំណុំរឿង ០០២ ប៉ុណ្ណោះ ដែលផ្តល់លទ្ធភាពឲ្យអង្គជំនុំជម្រះអាចចេញសាលក្រមដំបូង ដែលកំណត់ត្រឹមបទចោទ និងការចោទប្រកាន់លើអង្គហេតុមួយចំនួន នៅដំណាក់កាលដំបូង ដោយមិនចាំបាច់រង់ចាំការបញ្ចប់ការជំនុំជម្រះទាំងមូល ទាក់ទិននឹងគ្រប់ផ្នែកទាំងអស់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ អង្គជំនុំជម្រះ យល់ឃើញថា បណ្តឹងសាទុក្ខណាមួយទៅលើសាលក្រមដំបូងនឹងមិនរារាំងការបន្តការជំនុំជម្រះជាបន្តបន្ទាប់លើសំណុំរឿង ០០២ ដែលទាក់ទិននឹងបទចោទ និងការចោទប្រកាន់លើអង្គហេតុដែលនៅសេសសល់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះឡើយ"*[6]។

---

[5] សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យពិចារណាឡើងវិញនូវខ្លឹមសារក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី លេខ E124 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ**E124/8** កថាខណ្ឌ ២៧។

[6] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរ

៧. នៅពេលនោះ អង្គជំនុំជម្រះ បានបញ្ជាក់ថា ការជំនុំជម្រះវគ្គទី ១ នឹងផ្តល់ជា "មូលដ្ឋាន" សម្រាប់ការជំនុំជម្រះវគ្គក្រោយៗទៀត[7]។

៨. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញា បានស្នើសុំពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ទៅដល់បទចោទ និងអង្គហេតុមួយចំនួនទៀត ដូចមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[8]។

៩. នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ក្នុងកិច្ចប្រជុំរៀបចំសវនាការស្តីពីលទ្ធភាពពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ដែលកំពុងជំនុំជម្រះ សហព្រះរាជអាជ្ញា បានលើកឡើងជាថ្មីម្តងទៀតអំពី *"ឧបសគ្គផ្លូវច្បាប់រារាំងដល់ការចាប់ផ្តើមសំណុំរឿង វគ្គទី ២ មុនពេលបញ្ចប់សំណុំរឿង វគ្គទី ១"* ជាឧបសគ្គដែលលោក Andrew CAYLEY *"មិនដឹងថាតើត្រូវពុះពារជម្នះតាមវិធីណា ដើម្បីឲ្យដំណើរការទៅមុខទៀត"*[9]។

១០. នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះ បានបដិសេធផ្នែកខ្លះ នៃសំណើសុំពង្រីកវិសាលភាពរបស់សហព្រះរាជអាជ្ញា[10]។

---

ការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/7** ("សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញនូវការបំបែកកិច្ចដំណើរការនីតិវិធី **E124/7**") កថាខណ្ឌ ៨។

[7] សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញនូវការបំបែកកិច្ចដំណើរការនីតិវិធី **E124/7** កថាខណ្ឌ ១០, ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តី នៃសំណុំរឿង ០០២, អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E131** កថាខណ្ឌ ៣។

[8] សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ឯកសារ **E163**។

[9] ប្រតិចារឹកសវនាការ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ **E1/114.1** ទំព័រ ៧៣ បន្ទាត់ ១១-២១ នៅចន្លោះពីម៉ោង [14.11.12] ដល់ម៉ោង [14.13.06]។

[10] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារ **E163/5**។

១១. នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញា បានប្ដឹងសាទុក្ខប្រឆាំងនឹងការបដិសេធផ្នែកខ្លះនេះ ដោយលើកឡើងថា បញ្ហាពាក់ព័ន្ធនឹងឧបសគ្គផ្លូវច្បាប់ដែលត្រូវពុះពារជម្នះ សម្រាប់ការជំនុំជម្រះសំណុំរឿង ០០២/០២ មិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ។ ខាងក្រោមនេះ គឺជាការរំឭកអំពីជំហររបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងប្រធានបទបញ្ហានេះ៖

> *"សហព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញថា វាអាចមានឧបសគ្គតាមផ្លូវច្បាប់ ក្នុងការប្រើប្រាស់មូលដ្ឋានអង្គហេតុ និងអង្គច្បាប់ ដែលបានមកពីសវនាការទីមួយ នៅក្នុងសវនាការជាបន្តបន្ទាប់មកទៀតនោះ។ វិធីសាស្ត្រនានា ដែលតាមរយៈនោះ គេអាចនឹងធ្វើសវនាការបន្តបន្ទាប់មកទៀតបានយ៉ាងឆាប់រហ័ស គឺជាការជូនដំណឹងតាមផ្លូវតុលាការនៃអង្គហេតុនានាដែលបានវិនិច្ឆ័យរួចហើយ និងអាជ្ញាអស់ជំនុំ។ យ៉ាងណាក៏ដោយ ក៏គោលការណ៍ទាំងនេះអាចនឹងត្រូវបានរារាំងតាមផ្លូវច្បាប់ ដោយអាស្រ័យលើសេចក្ដីសម្រេចចុងក្រោយលើបណ្ដឹងសាទុក្ខក្នុងដំណាក់កាលសវនាការដំបូង។ (...) ដូច្នេះ មានបញ្ហាមួយចំនួនដែលទាក់ទងនឹងលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការទាញយកផលប្រយោជន៍ពីយន្តការទាំងនេះ នៅមុនពេលចេញសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខ។ បញ្ហាសក្ដានុពលតាមផ្លូវច្បាប់ដែលអាចមានផលប៉ះពាល់ទៅលើសវនាការទី ២ រួមមានការលើកលែងទោស និងការអនុគ្រោះទោស និយមន័យនៃឧក្រិដ្ឋកម្មអន្តរជាតិ ទម្រង់នៃការទទួលខុសត្រូវ និងភាពអាចទទួលយកបាន និងការប្រើប្រាស់ដ៏ត្រឹមត្រូវនៃភស្តុតាង"*
> [11]។

១២. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានធ្វើមោឃភាពដីកាសម្រេចបំបែកកិច្ចដំណើការនីតិវិធី ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ របស់អង្គជំនុំជម្រះសាលាដំបូង ដោយបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុស ដោយសារមិនបានឆ្លើយតបទៅនឹងសំណួរ ដែលសហព្រះរាជអាជ្ញា និងសហមេធាវីនាំតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានលើកឡើង នៅក្នុងសំណើរៀងៗខ្លួន សុំឲ្យពិចារណាឡើងវិញនូវដីកាសម្រេចបំបែកកិច្ចដំណើការនីតិវិធី ឆ្នាំ ២០១១។ អង្គជំនុំជម្រះតុលាការកំពូល ក៏យល់ឃើញផងដែរថា *"ក្នុងករណីមានការបន្ត*

---

[11] បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចស្ដីពីវិសាលភាពនៃការជំនុំជម្រះក្ដី នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ **E163/5/1/1** កថាខណ្ឌ ១៨ និងកំណត់សម្គាល់ជើងទំព័រលេខ ៤២។

*ការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ អ.វ.ត.ក គប្បីបង្កើតឲ្យមានអង្គចៅក្រមជំនុំជម្រះមួយទៀត នៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីគាំទ្រដល់ការជំនុំជម្រះឲ្យបានទាន់ពេលទៅលើផ្នែកដែលនៅសេសសល់នៃសំណុំរឿង ០០២"*។

១៣. នៅថ្ងៃទី ១៨ និងថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ក្នុងសវនាការស្ដីពីផលវិបាកនៃការធ្វើមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី ទាំងសហព្រះរាជអាជ្ញា[12] ទាំងដើមបណ្ដឹងរដ្ឋប្បវេណី[13] ក៏ដូចជាមេធាវីការពារលោក នួន ជា[14] និងមេធាវីការពារក្ដីលោក ខៀវ សំផន[15] បានបញ្ចេញទស្សនៈរបស់ខ្លួនថា វាជាការពិបាកណាស់ក្នុងការធ្វើអ្វីផ្សេង ក្រៅតែពីការរង់ចាំសាលដីកាលើបណ្ដឹងសាទុក្ខនៃសំណុំរឿង ០០២/០១ សិន មុននឹងចាប់ផ្ដើមសំណុំរឿង ០០២/០២។

១៤. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះ បានបំបែកបទចោទជាថ្មីម្ដងទៀត (រក្សាទុកវិសាលភាពនៃការជំនុំជម្រះ វគ្គទី ១ នៅដដែល ដូចបានកំណត់នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២) ដោយប្រកាសថា៖

> *"អង្គជំនុំជម្រះសាលាដំបូង នឹងរៀបចំឲ្យមានកិច្ចប្រជុំរៀបចំសវនាការមួយ នៅចុងឆ្នាំនេះ នៅពេលបញ្ហានានាតម្រូវឲ្យមានការពិនិត្យមើលឡើងវិញ ដោយសារតែការកែប្រែស្ថានភាពនានាដែលអាចកើតមាន។ ក្នុងពេលនេះ អង្គជំនុំជម្រះសាលាដំបូង សូមគូសបញ្ជាក់ថា បទចោទប្រកាន់នានា និងការចោទប្រកាន់លើអង្គហេតុ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០២មិនត្រូវបានច្រានចោល ដោយសារតែការ*

[12] ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E1/171.1** ទំព័រ ៦៨ បន្ទាត់ ១៥ ដល់ទំព័រ ៧០ បន្ទាត់ ៥ នៅចន្លោះពីម៉ោង [15.15.32] ដល់ម៉ោង [15.21.14]។

[13] ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E1/171.1** ទំព័រ ៧០ បន្ទាត់ ១០-២២ នៅចន្លោះពីម៉ោង [15.21.14] ដល់ម៉ោង [15.22.46]។

[14] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E1/172.1** ទំព័រ ១៧ បន្ទាត់ ១៥ ដល់ទំព័រ ១៨ បន្ទាត់ ១០ នៅចន្លោះពីម៉ោង [09.56.03] ដល់ម៉ោង [09.58.31]។

[15] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E1/172.1** ទំព័រ ៤៥ បន្ទាត់ ១៣-២៥ នៅចន្លោះពីម៉ោង [11.50.38] និងម៉ោង [11.52.21], ទំព័រ ៥២ បន្ទាត់ ៥-៨ ប្រហែលម៉ោង [13.38.54]។

*ចេញសេចក្ដីសម្រេចនេះឡើយ"* [16]។

១៥. ដូច្នេះ អង្គជំនុំជម្រះ បានជៀសវាងមិនឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃការជំនុំជម្រះក្ដីវគ្គក្រោយៗទៀត។

១៦. នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញា បានប្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចថ្មីស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី ដោយបានសម្ដែងការមិនពេញចិត្តចំពោះការមិនឆ្លើយតបរបស់អង្គជំនុំជម្រះទៅនឹងសំណួរទាំងនេះ[17]។

១៧. នៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៣ មេធាវីការពារក្ដីលោក ខៀវ សំផន បានប្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចបដិសេធសំណើសុំដោះលែងឲ្យនៅក្រៅឃុំ និងបានសម្ដែងការមិនពេញចិត្តចំពោះភាពស្ងៀមស្ងាត់របស់អង្គជំនុំជម្រះទៅលើសំណួរទាំងនេះ[18]។

១៨. នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ មេធាវីការពារក្ដីលោក នួន ជា បានប្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចថ្មីស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី ហើយបានសម្ដែងការមិនពេញចិត្តផងដែរចំពោះការមិនឆ្លើយតបរបស់អង្គជំនុំជម្រះទៅនឹងសំណួរទាំងនេះ[19]។

---

[16] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E284** ("សេចក្ដីសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មី **E284**") កថាខណ្ឌ ១៥៤-១៥៥។

[17] បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរ ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E284/2/1** កថាខណ្ឌ ៧៨។

[18] បណ្ដឹងសាទុក្ខរបស់លោក ខៀវ សំផន ប្រឆាំងទៅនឹងសេចក្ដីសម្រេចលើសំណើសុំដោះលែងឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E275/2/1** កថាខណ្ឌ ៦៨-៦៩។

[19] បណ្ដឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជំទាស់នឹងសេចក្ដីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E284/4/1** កថាខណ្ឌ ៦ និងកថាខណ្ឌ ២៤។

១៩. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ក្នុងកិច្ចប្រជុំរៀបចំសវនាការស្ដីពីដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២/០១ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានសួរអង្គជំនុំជម្រះថា តើអង្គជំនុំជម្រះមានចម្លើយទៅនឹងបញ្ហាអាជ្ញាអស់ជំនុំ ដែរឬទេ[20]។ ពេលនោះ លោកស្រីចៅក្រម Silvia CARTWRIGHT បានឆ្លើយតបទៅវិញថា៖

> *"តបទៅនឹងសំណួរទីពីរ ដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានសួរចង់ដឹងថា តើអង្គជំនុំជម្រះមានជំហរដូចម្ដេចពាក់ព័ន្ធនឹងអាជ្ញាអស់ជំនុំ ក្នុងសំណុំរឿង ០០២/០២ និងសំណុំរឿងវគ្គបន្តបន្ទាប់ទៀត អង្គជំនុំជម្រះយល់ឃើញថាវាឆាប់ពេកក្នុងការពិភាក្សាពីបញ្ហាទាំងអស់នេះ នៅថ្ងៃនេះ។ ទីមួយ យើងត្រូវរង់ចាំសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលសិន ដែលនឹងអាចបំភ្លឺបញ្ហាមួយចំនួន។ ទីពីរ យើងបានចង្អុលបង្ហាញជូនភាគីរួចហើយថា បន្ទាប់ពីសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះនឹងបើកកិច្ចប្រជុំរៀបចំសវនាការមួយ ដើម្បីពិភាក្សាលើបញ្ហាមួយចំនួន ដូចជា អាជ្ញាអស់ជំនុំ ជាដើម ហើយភាគីនឹងអាចលើកឡើងនូវបញ្ហាផ្សេងទៀត។ ខ្ញុំសង្ឃឹមថាចម្លើយនេះគ្រប់គ្រាន់ហើយ"*[21]។

២០. នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ជាថ្ងៃចុងក្រោយនៃសវនាការលើអង្គសេចក្ដី ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្ដីសង្ខេបនៃសំអាងហេតុនៃសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុស ដោយសារមិនបានពិចារណាលើ *"សំណើ និងការបារម្ភរបស់ភាគី ទាក់ទងនឹងបច្ច័យនៃការបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី សម្រាប់ការជំនុំជម្រះណាមួយនាពេលអនាគតនោះ"*។ អង្គជំនុំជម្រះតុលាការកំពូល បានបន្ថែមទៀតថា សំណុំរឿង ០០២/០២ ត្រូវ *"ចាប់ផ្ដើមឲ្យបានឆាប់រហ័សបំផុតតាម*

---

[20] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៣៨ បន្ទាត់ ៤-១១ នៅចន្លោះពីម៉ោង [11.17.53] ដល់ម៉ោង [11.19.22]។

[21] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៣៩ បន្ទាត់ ៩-២០ នៅចន្លោះពីម៉ោង [11.23.21] ដល់ម៉ោង [11.24.58]។

*ដែលអាចធ្វើទៅបាន"* ហើយការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ *"ក្លាយជាបញ្ហាសំខាន់"*[22]។

២១. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញា បានស្នើសុំថារបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការ នៅខែ ធ្នូ ឆ្នាំ ២០១៣៖

> *"ដាក់បញ្ចូលផងដែរនូវការពិភាក្សាពីផលប៉ះពាល់នៃការរកឃើញអង្គហេតុទានា ក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ ទៅលើសំណុំរឿង ០០២/០២។ តាមជំហររបស់សហព្រះរាជអាជ្ញា គឺថាគេពុំចាំបាច់ធ្វើសច្ចទស្សន៍តុលាការណាមួយអំពីការរកឃើញផ្នែកអង្គហេតុ ដែលគេបានជម្រះរួចហើយពីសំណុំរឿង ០០២/០១ ឡើយ។ ផ្ទុយទៅវិញ ការរកឃើញអង្គហេតុ និងសាលក្រមនៃសំណុំរឿង ០០២/០២ គួរផ្អែកលើសក្ខីកម្ម ឯកសារ និងភស្តុតាងដទៃទៀត ដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធីទាំងនោះ រួមមានទាំងភស្តុតាងដែលមាននៅក្នុងកំណត់ហេតុ ដែលបានបង្ហាញនៅក្នុងសំណុំរឿង ០០២/០១"*[23]។

២២. នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានចេញសំអាងហេតុទាំងស្រុងនៃសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខ ប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មី។ អង្គជំនុំជម្រះតុលាការកំពូល បានស្តីបន្ទោសដល់អង្គជំនុំជម្រះសាលាដំបូងថា មិនបានដោះស្រាយលើ *"បញ្ហាចោទថាតើសំណុំរឿង ០០២/០២ អាចនឹងចាប់ផ្តើមនៅពេលណា ហើយកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទដែលនៅសល់ អាចបញ្ចប់ដោយរបៀបណា"* និង *"បង្ហាញនូវភាពមិនច្បាស់លាស់សម្រាប់ភាគី"*។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូល មិនបានពន្យល់អំពីរបៀបដែលសំណុំរឿង០០២/០២ អាចចាប់ផ្តើម *"ឲ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន បន្ទាប់*

---

[22] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២ - <u>សេចក្តីសង្ខេបនៃសំអាងហេតុ</u> ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E284/4/7** ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី - សេចក្តីសង្ខេបនៃសំអាងហេតុ **E284/4/7**") កថាខណ្ឌ ៩ កថាខណ្ឌ ១០ កថាខណ្ឌ ១១។

[23] មតិរបស់សហព្រះរាជអាជ្ញា លើរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការសម្រាប់សំណុំរឿង ០០២/០២ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **E301/1** កថាខណ្ឌ ៣។

*ពីបញ្ចប់សារណាបិទការពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០១"* ដោយមិនចាំបាច់រង់ចាំសាលក្រមស្ថាពរនៃសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះតុលាការកំពូល បានត្រឹមតែស្នើឱ្យប្រធានអង្គជំនុំជម្រះសាលាដំបូង *"ពិនិត្យលទ្ធភាពដែលមានស្រាប់"* ដើម្បីតែងតាំងក្រុមប្រឹក្សាជំនុំជម្រះ ទីពីរ ដែលនឹងអាច *"ចាប់ផ្ដើមភ្លាមៗផងដែរ ក្នុងការជំនុំជម្រះលើកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់ទៀត"*[24]។

២៣. នៅថ្ងៃទី ១១ និងថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ក្នុងកិច្ចប្រជុំរៀបចំសវនាការ ភាគីបានបញ្ចេញមតិជាអាទិ៍ពាក់ព័ន្ធនឹង *"លទ្ធភាពដែលមានស្រាប់"* របស់ប្រធានអង្គជំនុំជម្រះ ក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះថ្មី។ ទោះបីជាបញ្ហានេះមិនស្ថិតនៅក្នុងរបៀបវារៈក៏ដោយ ក៏មេធាវីការពារក្ដីលោក ខៀវ សំផន បានលើកឡើងម្ដងទៀតនូវទស្សនៈរបស់ខ្លួនដែលថា សំណុំរឿង ០០២/០២ មិនអាចចាប់ផ្ដើម មុនពេលសាលក្រមនៃសំណុំរឿង ០០២/០១ ចូលជាស្ថាពរ នោះទេ[25]។

២៤. នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៣ ប្រធានអង្គជំនុំជម្រះ បានប្រកាសថា *"ក្របខ័ណ្ឌច្បាប់នេះមិនមានភាពច្បាស់លាស់ ក្នុងការបង្ហាញថាតើមានមូលដ្ឋានច្បាប់ សម្រាប់ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដែរឬយ៉ាងណា"* ហើយសមត្ថកិច្ចរបស់ប្រធានអង្គជំនុំជម្រះក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរ ក៏មានភាពមិនច្បាស់លាស់ដែរ។ ប្រធានអង្គជំនុំជម្រះយល់ឃើញថា *"ការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរ (...) ដើម្បីជំនុំជម្រះលើការចោទប្រកាន់នានាដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០២ នឹងមិនបម្រើផលប្រយោជន៍យុត្តិធម៌ទេ"*[26]។

---

[24] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី នៃសំណុំរឿង ០០២, អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **E284/4/8** ("សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8**") ជាអាទិ៍ កថាខណ្ឌ ៦៩ កថាខណ្ឌ ៧២ កថាខណ្ឌ ៧៣ កថាខណ្ឌ ៧៤។

[25] ប្រតិចារឹកសវនាការ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **E1/238.1**, ប្រតិចារឹកសវនាការ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **E1/238.2**។

[26] អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរ នៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីជំនុំជម្រះលើការចោទប្រកាន់ដែលមិនទាន់ត្រូវបានជំនុំជម្រះ នៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **E301/4** ជាអាទិ៍ កថាខណ្ឌ ៣ និងកថាខណ្ឌ ១០។

## II. ភាពចាំបាច់ក្នុងការរង់ចាំសាលក្រមស្ថាពរ

២៥. ដោយសារការបំបែកកិច្ចដំណើរការនីតិវិធី ដែលបានអនុវត្តនៅក្នុងសំណុំរឿង ០០២ គោលការណ៍អាជ្ញាអស់ជំនុំ និងសច្ចភាពគតិយុត្ត តម្រូវឱ្យរង់ចាំសេចក្តីសម្រេចស្ថាពរ ក្នុងសំណុំរឿង ០០២/០១ មុននឹងចាប់ផ្តើមសំណុំរឿង ០០២/០២ ទោះបីជាសំណុំរឿងក្រោយនេះ ត្រូវជំនុំជម្រះដោយចៅក្រមផ្សេង ឬក៏ចៅក្រមដដែលក៏ដោយ។

## ក. ការបំបែកការជំនុំជម្រះក្តីជាវគ្គតូចៗ

២៦. ក្នុងប្រព័ន្ធយុត្តិធម៌ ការបំបែកកិច្ចដំណើរការនីតិវិធី គឺជាការបំបែក (ឬការអង្គុន់) បទចោទប្រកាន់ ។ ដូច្នេះ បទចោទប្រកាន់ដែលត្រូវបានបំបែក ត្រូវបានជំនុំជម្រះ និងវិនិច្ឆ័យ ជារឿងក្តីច្រើនដាច់ៗពីគ្នា និងមិនមែនក្នុងរឿងក្តីទាំងមូលតែមួយ និងដូចគ្នានោះឡើយ។ បទចោទប្រកាន់ទាំងនោះ អាចនឹងត្រូវជំនុំជម្រះ និងវិនិច្ឆ័យដោយចៅក្រមដដែល ឬចៅក្រមផ្សេង។

២៧. នៅចំពោះមុខ អ.វ.ត.ក (ដែលមានតែអង្គជំនុំជម្រះសាលាដំបូងតែមួយគត់ ដែលត្រូវជំនុំជម្រះលើជនជាប់ចោទមួយរូប ឬច្រើនរូប[27]) វិធាន ៨៩ *ស្ទួនពីរ* ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី នៃវិធានផ្ទៃក្នុង ចែងថា៖

> *"នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬ ច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីដែលត្រូវបានបំបែក ត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយ ដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប"*[28]។

---

[27] វិធាន ៩៨(២) និង ៩៨(៣) នៃវិធានផ្ទៃក្នុង។

[28] បទប្បញ្ញត្តិនេះជាភាសាអង់គ្លេស សរសេរថា "*When the interest of justice so requires, the Trial Chamber may at any stage order the separation of proceedings in relation to one or several accused and concerning part or the entirety of the charges contained in an Indictment. The cases as separated shall be tried and adjudicated in such order as the Trial Chamber deems appropriate*"។

២៨. ក្នុងករណីបំបែកកិច្ចដំណើរការនីតិវិធី ដីកាដំណោះស្រាយតែមួយ និងដូចគ្នា នាំឲ្យមានរឿងក្តីដាច់ៗគ្នា និងខុសៗគ្នា លើជនជាប់ចោទ ឬអង្គហេតុទាំងឡាយ ដែលពាក់ព័ន្ធនឹងបទចោទប្រកាន់ផ្សេងៗគ្នា (ដែលជាកម្មវត្ថុនៃការពិភាក្សាដាច់ដោយឡែកពីគ្នា)។ សាលក្រមដោយឡែកមួយ នឹងត្រូវចេញនៅពេលបញ្ចប់រឿងក្តីនីមួយៗ។

២៩. ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះ បានអនុវត្តការបំបែកកិច្ចដំណើរការនីតិវិធី ជាពីរប្រភេទ ដែលមានចែងក្នុងវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះ បានបំបែកបទចោទប្រកាន់ និងអង្គហេតុដែលពាក់ព័ន្ធនឹងបទចោទទាំងអស់នោះ[29] ប៉ុន្តែ អង្គជំនុំជម្រះ ក៏បានបំបែកជនជាប់ចោទផងដែរ[30]។ បន្ទាប់ពីបទចោទប្រកាន់ប្រឆាំងនឹងលោកស្រី អៀង ធីរិទ្ធ ត្រូវបានបំបែកចេញពីសំណុំរឿង[31] ករណីរបស់ជនជាប់ចោទរូបនេះ ត្រូវបានអង្គជំនុំជម្រះពិនិត្យដាច់ដោយឡែកពីសំណុំរឿង ០០២/០១។

៣០. តាមរយៈការបង្គាប់ឲ្យបំបែកបទចោទ និងការចោទប្រកាន់ អង្គជំនុំជម្រះបានសម្រេចថាខ្លួននឹងជំនុំជម្រះបទចោទប្រកាន់ទាំងនោះបន្តបន្ទាប់គ្នា ជារឿងក្តីមួយម្តងៗ។ ការបំបែកបទចោទប្រកាន់ដែលបានអនុវត្តដូច្នេះ ត្រូវបានឯកភាពដោយអង្គជំនុំជម្រះតុលាការកំពូល[32]។ ក្នុងរឿងក្តីទាំងនេះ ដែលចាប់ពីពេលនេះទៅត្រូវក្លាយជារឿងក្តីខុសៗគ្នា និងបន្តបន្ទាប់គ្នា ភាគីទាំងអស់ក្នុងដំណើរការនីតិវិធី នៅរក្សាដដែល ប៉ុន្តែ អង្គហេតុ និងបទចោទប្រកាន់ គឺខុសៗគ្នា។

---

[29] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E124, សេចក្តីសម្រេចថ្មីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E284។

[30] សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E138។

[31] សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E138 កថាខណ្ឌ ៦១។

[32] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២ - សេចក្តីសង្ខេបនៃសំអាងហេតុ ឯកសារ E284/4/7, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ឯកសារ E284/4/8។

៣១. ផ្ទុយទៅវិញ ទោះបីជាអង្គហេតុនៃការជំនុំជម្រះខុសគ្នាក៏ដោយ ក៏ លោក នួន ជា និង លោក ខៀវ សំផន នៅតែត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តរាល់ឧក្រិដ្ឋកម្មទាំងឡាយ ដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ ក្នុងបរិបទនៃការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ ប្រឆាំងនឹងប្រជាជនស៊ីវិលកម្ពុជា ("ធាតុផ្សំជាមូលដ្ឋាន") និងសហឧក្រិដ្ឋកម្មរួម។

៣២. បញ្ហាចំបង ដែលត្រូវបានចោទឡើងដោយការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវបានលើកឡើងជាច្រើនដងដោយក្រុមមេធាវីការពារក្តី[33]។ បញ្ហានេះពាក់ព័ន្ធជាពិសេស ជាមួយជនជាប់ចោទ ព្រោះថាវាជាធាតុផ្សំដែលអង្គជំនុំជម្រះនឹងត្រូវប្រកាន់យក ដើម្បីកំណត់ពីទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាយថាហេតុណាមួយ ជាពិសេស គឺសហឧក្រិដ្ឋកម្មរួម។ ជំហររបស់អង្គជំនុំជម្រះនៅតែមិនទាន់ច្បាស់លាស់។ ផ្ទុយទៅវិញ ចាប់តាំងពីការបំបែកកិច្ចដំណើរការនីតិវិធីមក ទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ដែលត្រូវបានរក្សាទុកដោយសហចៅក្រមស៊ើបអង្កេត និងដែលត្រូវបានលើកឡើងវិញដោយសហព្រះរាជអាជ្ញា គឺពិតជាពុំត្រឹមត្រូវតាមច្បាប់ឡើយ។

៣៣. នៅថ្ងៃនេះ ក្រុមមេធាវីការពារក្តី ត្រូវធ្វើលំហាត់មួយដ៏លំបាក ព្រោះថាខ្លួនពុំបានដឹងពីសេចក្តីសម្រេច ដែលអង្គជំនុំជម្រះនឹងត្រូវចេញលើចំណុចនេះនៅឡើយ។ ប្រសិនបើ អង្គជំនុំជម្រះរក្សាទុកការទទួលខុសត្រូវរបស់សហជនជាប់ចោទ លើមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម ដោយផ្អែកលើនយោបាយឧក្រិដ្ឋទាំងប្រាំ ដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ ខណៈដែលមានតែនយោបាយពីរប៉ុណ្ណោះ ក្នុងចំណោមនយោបាយទាំងប្រាំ ដែលត្រូវបានលើកឡើង (មួយផ្នែក) ក្នុងការជំនុំជម្រះដំណាក់កាលទីមួយនោះ ក្រុមមេធាវីការពារក្តី នឹងប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម។ របៀបរបបនៃការដឹកនាំកិច្ចពិភាក្សាក្នុងរឿងក្តីដំណាក់កាលទីពីរ ប្រាកដជានឹងត្រូវប៉ះពាល់ដោយសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវ ទាំងលើរបៀបនៃការបង្ហាញភ័ស្តុតាងពាក់ព័ន្ធលើចំណុចនេះ ឬលើវិសាលភាពនៃសំណុំរឿងទីពីរ។

---

[33] សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១៣ ឯកសារ E275/2/1/1 កថាខណ្ឌ ១៩ ដល់កថាខណ្ឌ ៦៨ និង ឯកសារបន្ថែម ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ E275/2/1/3, សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ E295/6/4, ប្រតិចារឹកសវនាការថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ E1/234.1។

៣៤. អង្គជំនុំជម្រះ បានសម្រេចអង្គន់ដីកាដំណោះស្រាយ និងបានបញ្ជាក់ពីមូលហេតុនៃការអង្គន់នេះតាមរយៈចេតនារបស់ខ្លួន៖

– *"ដើម្បីផ្តល់នូវ**មូលដ្ឋាន**សម្រាប់ការពិនិត្យលម្អិតលើបទចោទ និងការចោទប្រកាន់នានា ដែលនៅសេសសល់ប្រឆាំងនឹងជនជាប់ចោទនៅក្នុងការជំនុំជម្រះលើកក្រោយ"*[34] ។

– *"ដើម្បីធានាតាមដែលអាចធ្វើទៅបានថា បញ្ហានានាដែលត្រូវបានពិនិត្យនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូង ផ្តល់នូវ**មូលដ្ឋាន**មួយសម្រាប់ការពិចារណាអំពីទម្រង់នៃការចូលរួមក្នុងឧក្រិដ្ឋកម្ម តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម [...] "*[35]។

៣៥. ក្នុងពេលជាមួយគ្នានោះ អង្គជំនុំជម្រះ បានប្រកាសថា[ខ្លួន] *"រំពឹងថា សវនាការដំណាក់កាលដំបូងនេះ នឹងផ្តល់ជា**មូលដ្ឋាន**រួមមួយសម្រាប់បទចោទទាំងអស់ រួមទាំងបទចោទនានាដែលអង្គជំនុំជម្រះ នឹងលើកយកទៅពិនិត្យក្នុងសវនាការដំណាក់កាលបន្ទាប់"*[36]។

៣៦. ក្រុមមេធាវីការពារក្តី ពុំបានដឹងអ្វីច្រើនពាក់ព័ន្ធនឹងសញ្ញាណនៃ "មូលដ្ឋានរួម" នេះឡើយ។ ក្រុមមេធាវីការពារក្តី បានកត់សម្គាល់ថា អង្គជំនុំជម្រះបានប្រើប្រាស់ពាក្យ *"តាមដែលអាចធ្វើទៅបាន"* ដែលអាចឲ្យយើងសន្និដ្ឋានបានថា អង្គជំនុំជម្រះ បានដឹងយ៉ាងច្បាស់ពីការលំបាកក្នុងការកម្រិតគោលការណ៍តទល់គ្នា ក្នុងរឿងក្តីមួយដែលផ្តាច់ចេញពីគេ។ ផ្ទុយទៅវិញ គឺតាមរយៈគោលការណ៍តទល់គ្នា និងសិទ្ធិក្នុងការឆ្លើយតបទៅនឹងបទចោទប្រកាន់ដាច់ៗពីគ្នា ក្នុងសំណុំរឿងទីពីរនេះ

[34] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពីល័ក្ខខ័ណ្ឌនានា នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ឯកសារ E124/7, កថាខណ្ឌ ១០។ យើងជាអ្នកសរសេរជាអក្សរដិត។

[35] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពីល័ក្ខខ័ណ្ឌនានា នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ឯកសារ E124/7, កថាខណ្ឌ ១០។ យើងជាអ្នកសរសេរជាអក្សរដិត។

[36] ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E131 កថាខណ្ឌ ៣។ យើងជាអ្នកសរសេរជាអក្សរដិត។

ហើយ ដែលក្រុមមេធាវីការពារក្ដី បានជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យផ្ទេរជាប្រព័ន្ធនូវភ័ស្ដុតាងពីសំណុំរឿង ០០២/០១ ទៅក្នុងសំណុំរឿង ០០២/០២[37]។

៣៧. លើសពីនេះទៅទៀត ក្រុមមេធាវីការពារក្ដី សូមរំឭកថា ក្នុងរឿងក្ដីមួយ ចៅក្រមអាចទាញយក ឬប្រើប្រាស់បញ្ហា និងអង្គហេតុនានា ដែលត្រូវបានជំនុំជម្រះរួចរាល់ក្នុងរឿងក្ដីមួយផ្សេងទៀត តែក្នុងល័ក្ខខ័ណ្ឌមួយចំនួនប៉ុណ្ណោះ ជាពិសេសក្នុងរឿងក្ដីដែលពាក់ព័ន្ធនឹងភាគីតែមួយ។

៣៨. ការកត់សម្គាល់នេះ គឺជាហេតុផលគាំទ្រដល់ការរង់ចាំសេចក្ដីសម្រេចស្ថាពរ មុននឹងចាប់ផ្ដើមសំណុំរឿងទីពីរ។ មូលហេតុ គឺថាប្រសិទ្ធិផលតុលាការ តម្រូវមិនឱ្យបើករឿងក្ដីទីពីរ ដោយផ្អែកលើមូលដ្ឋានគតិយុត្តដែលអាចខុសឆ្គងជាយថាហេតុបានឡើយ។ ប៉ុន្ដែ ប្រសិនបើអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសលើអង្គច្បាប់ក្នុងរឿងក្ដីទីមួយ ល័ក្ខខ័ណ្ឌដែលកិច្ចពិភាក្សានឹងត្រូវដឹកនាំធ្វើក្នុងរឿងក្ដីទីពីរ ប្រាកដជាមានកំហុសដូចគ្នា។ ស្ថានភាពបែបនេះ នឹងមិនធានាបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងការពិភាក្សាឆាប់រហ័សនោះឡើយ។

៣៩. ភាពអន្ទះសា នឹងបង្កឱ្យមានភាពប្រថុយប្រថាននឹងការធ្វើឱ្យដួលរលំស្ថាប័នតុលាការទាំងមូល មានន័យថា វាអាចបង្កើតបានជាលទ្ធផលបញ្ច្រាសគ្នានឹងអ្វីដែលយើងកំពុងស្វែងរក។

៤០. ដរាបណាអង្គហេតុដែលត្រូវបានជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ មិនទាន់ត្រូវបានទទួលយក ឬវិនិច្ឆ័យជាស្ថាពរនោះទេ យើងមិនអាចចាប់ផ្ដើមសំណុំរឿង ០០២/០២ ដោយផ្ដើមចេញពី "មូលដ្ឋានរួមមួយ" ដែលផ្ដល់ដោយតាមរយៈសំណុំរឿង ០០២/០១ នោះទេ។

៤១. រាល់ការកត់សម្គាល់ខាងលើ ក៏សមស្របផងដែរសម្រាប់ធាតុផ្សំជាមូលដ្ឋាន។

---

[37] ចម្លើយរបស់ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ទៅនឹង "សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្ដីពីការប្រើប្រាស់ភ័ស្ដុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មី ពីសំណុំរឿង ០០២/០១ ទៅក្នុងសំណុំរឿងលេខ ០០២/០២" ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៣ ឯកសារ E302/1។

## ខ. គោលការណ៍អាជ្ញាអស់ជំនុំ និងសច្ចភាពគតិយុត្ត

៤២. អនុលោមតាមគោលការណ៍អាជ្ញាអស់ជំនុំ និងសច្ចភាពគតិយុត្ត គឺតម្រូវឲ្យសម្រេចជាស្ថាពរលើអង្គហេតុពាក់ព័ន្ធទាំងឡាយ ដែលត្រូវបានពិភាក្សាក្នុងសំណុំរឿង ០០២/០១ និងបានប្រើប្រាស់ជា "មូលដ្ឋាន" ក្នុងការជំនុំជម្រះសំណុំរឿង ០០២/០២ មុននឹងចាប់ផ្តើមការជំនុំជម្រះលើសំណុំរឿង ០០២/០២។ លើសពីនេះទៅទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល នឹងអាចកំណត់បានជាស្ថាពរនូវវិសាលភាពពិតប្រាកដ និងជាក់ស្តែងនៃសំណុំរឿង ០០២/០១។

### ១. គោលការណ៍អាជ្ញាអស់ជំនុំ និងកិច្ចពិភាក្សាមុនៗ

៤៣. គោលការណ៍អាជ្ញាអស់ជំនុំ អាចត្រូវឲ្យនិយមន័យបានថា *"ជាបណ្តុំនៃអំណាច ភ្ជាប់ទៅនឹងសេចក្តីសម្រេចតុលាការដែលជាសច្ចភាពច្បាប់"*[38]។ គុណភាពនេះដែលត្រូវផ្តល់ដល់គ្រប់សេចក្តីសម្រេចតុលាការ ពាក់ព័ន្ធនឹងការតវ៉ា ដែលត្រូវបានកាត់សេចក្តីដោយសេចក្តីសម្រេចនោះ *"ហាមមិនឲ្យរឿងរ៉ាវតែមួយ ត្រូវយកមកជំនុំជម្រះសាជាថ្មី រវាងភាគីតែមួយ ក្នុងរឿងក្តីមួយផ្សេងទៀត ដោយទុកផ្លូវប្តឹងតវ៉ា"*[39]។

៤៤. មូលដ្ឋាននៃគោលការណ៍នេះ ដែលបានសម្តែងតាមបុរាណភាសិតឡាតាំង *res judicata pro veritate habetur* ou *res judicata pro veritae accipitur* (ដែលមានន័យថា៖ "រឿងរ៉ាវដែលត្រូវបានជំនុំជម្រះរួចរាល់ហើយ ត្រូវចាត់ទុកថាជាសច្ចភាព"[40]) គឺជាការការពារសេចក្តីសម្រេចតុលាការ និងសច្ចភាពគតិយុត្ត។ យោងតាម តុលាការសិទ្ធិមនុស្សអឺរ៉ុប៖

---

[38] សៀវភៅ វាក្យស័ព្ទច្បាប់ និពន្ធដោយលោក G. CORNU ន័យទីប្រាំរបស់ពាក្យ Autorité [de la chose jugée] បោះពុម្ពឆ្នាំ ២០០៣ គ្រឹះស្ថានបោះពុម្ពផ្សាយ PUF ។

[39] សៀវភៅ វាក្យស័ព្ទច្បាប់ និពន្ធដោយលោក G. CORNU ន័យទីពីររបស់ពាក្យ Chose [autorité de la chose jugée] បោះពុម្ពឆ្នាំ ២០០៣ គ្រឹះស្ថានបោះពុម្ពផ្សាយ PUF ។

[40] *រដ្ឋអាជ្ញា តទល់នឹង Delalic និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-21-T សាលក្រម ចុះថ្ងៃ ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ("សាលក្រមរឿងក្តី *Delalic*") កថាខណ្ឌ ២២៨ និងកំណត់សម្គាល់ជើងទំព័រលេខ ២៦០។

*"មូលដ្ឋានមួយក្នុងចំណោមមូលដ្ឋាននៃឧត្តមភាពច្បាប់ គឺជាគោលការណ៍សុវត្ថិភាពនៃទំនាក់ទំនងគតិយុត្ត ដែលចង់ឲ្យសេចក្តីសម្រេចស្ថាពរដែលចេញសម្រាប់ជម្លោះទាំងអស់ដោយតុលាការផ្សេងៗ មិនត្រូវបានចោទឡើងជាបញ្ហាសាជាថ្មី"*[41]។

៤៥. ជាលទ្ធផល គោលការណ៍អាជ្ញាអស់ជំនុំ អាចត្រូវបានកំណត់ថាមានភាព "វិជ្ជមាន" និង "អវិជ្ជមាន"៖ វិជ្ជមាន ដោយសាថា វាបានសម្រួលប្រសិទ្ធភាពរបស់តុលាការ ដោយជៀសវាងការពិភាក្សាមិនសមហេតុផល ហើយអវិជ្ជមាន ព្រោះថាវាជាឧបសគ្គដល់ការពិភាក្សាថ្មីៗលើអង្គហេតុ ដែលត្រូវបានជំនុំជម្រះរួចហើយ។

៤៦. ក្នុងរឿងក្តីព្រហ្មទណ្ឌ ការការពារសេចក្តីសម្រេចតុលាការ ដោយគោលការណ៍អាជ្ញាអស់ជំនុំ បង្កើតឲ្យមានការការពារពីរ៖ មួយផ្នែក គឺការពារផលប្រយោជន៍ និងយុត្តិធម៌សង្គម ហើយមួយផ្នែកទៀត គឺការពារផលប្រយោជន៍បុគ្គល ឬការការពារខ្លួន។

៤៧. គោលការណ៍អាជ្ញាអស់ជំនុំ មាននៅគ្រប់ប្រព័ន្ធគតិយុត្ត ទាំងក្នុងប្រព័ន្ធជាតិ និងអន្តរជាតិ ក្នុងប្រព័ន្ធដែលដឹកនាំដោយចៅក្រម ក៏ដូចជាក្នុងប្រព័ន្ធប្រតិបក្ខ ទាំងក្នុងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌ។ ទោះបីជាគេឃើញមានគោលការណ៍នេះ ក្រោមរូបភាពផ្សេងៗគ្នា ឬក្លាយខ្លះ ដូចជាគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ឬក៏ "គោលការណ៍ពាក់ព័ន្ធនឹងការមិនទទួលបណ្តឹងជាថ្មី"នៃប្រព័ន្ធប្រតិបក្ខក៏ដោយ ក៏មូលដ្ឋាននៃការការពារសេចក្តីសម្រេចតុលាការនៅតែនៅដដែល គ្មានការប្រែប្រួល។ ផលវិបាករបស់មូលដ្ឋាននេះ ក៏ដូចគ្នាដែរ។

៤៨. ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍អាជ្ញាអស់ជំនុំ គឺជាវិធាន និងយុត្តិសាស្ត្រ[42]។ ឧទាហរណ៍ តុលាការពិសេសទាំងអស់ យល់ឃើញថា គោលការណ៍នេះ "នាំទៅដល់សំណួរដែល

---

[41] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Brumărescu តទល់នឹង* Roumanie (**បណ្តឹងលេខ ២៨៣៤២/៩៥) ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៦១។**

[42] ឧទាហរណ៍ សូមមើល៖ សាលក្រមក្នុងរឿងក្តី *Delalic* កថាខណ្ឌ ២២៨, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Simic និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ IT-95-9-PT សេចក្តីសម្រេចពាក់ព័ន្ធនឹង ១) សំណើរបស់ Stevan Torodovic សុំឲ្យពិនិត្យឡើងវិញ

ចង់ដឹងថា តើបញ្ហានេះត្រូវបានដោះស្រាយរួចរាល់ចប់សព្វគ្រប់ហើយឬនៅ នៅពេលដែលបុគ្គលតែម្នាក់ត្រូវជំនុំជម្រះជាលើកទីពីរ"[43]។ តុលាការពិសេសទាំងអស់ បានទាញយកប្រយោជន៍ពីសញ្ញាណមួយនេះក្នុងន័យ "វិជ្ជមាន" (ប្រសិទ្ធភាពតុលាការ និងសុខដុមនីយកម្មយុត្តិសាស្ត្រ[44]) តាមរយៈយន្តការនៃការកត់សម្គាល់តាមផ្លូវតុលាការ នូវអង្គហេតុទាំងឡាយដែលបានដឹងឮជាសាធារណៈ ឬអង្គហេតុដែលត្រូវបានទទួលយកនៅក្នុងរឿងក្តីផ្សេងៗទៀត។

៤៩. ក្នុងករណីទីមួយ វាគឺជាអង្គហេតុ *"ដែលគេបានដឹង និងដែលគ្មានហេតុផលក្លាយជាកម្មវត្ថុនៃការតវ៉ា"* (ឧទាហរណ៍ អង្គហេតុទាំងឡាយដែល "មិនត្រូវបានទទួលយករួមគ្នា ឬ មិនត្រូវបានទទួលស្គាល់ជាសាកល ដូចជា ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ទិន្នន័យភូមិសាស្ត្រ ឬច្បាប់ធម្មជាតិ

---

សេចក្តីសម្រេច ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៩, ២) សំណើរបស់ CICR សុំឱ្យពិនិត្យឡើងវិញលើដីកាសម្រេចលើកាលបរិច្ឆេទសវនាការ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ និង ៣) ល័ក្ខខ័ណ្ឌសុំចូលមើលឯកសារ, ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០០ កថាខណ្ឌ ៩ ដល់កថាខណ្ឌ ១០, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Bizimungu *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-99-50-T, *Decision on Prosper Mugiraneza's Second Motion to Dismiss for Deprivation of his Right to Trial Without Undue Delay* ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៧ កថាខណ្ឌ ៦, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Karemera *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-98-44-T សេចក្តីសម្រេចលើសំណើរបស់ Joseph Nzirorera សុំឱ្យដកការចោទប្រកាន់ថាបានត្រូវរ៉ូវគ្នាជាមួយ Juvenal Kajelijeli ស្របតាមគោលការណ៍អាជ្ញាអស់ជំនុំ (« *Collateral Estoppel* ») ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ ៤, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Karadzic សំណុំរឿងលេខ IT-95-5/18-T, *Decision on Accused's Motion to Strike Scheduled Shelling Incident on Grounds of Collateral Estoppel* ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១០ កថាខណ្ឌ ៥។

[43] សាលក្រមក្នុងរឿងក្តី *Delalic* កថាខណ្ឌ ២២៨។

[44] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krajisnik* សំណុំរឿងលេខ IT-00-39-PT សេចក្តីសម្រេចលើសំណើនានារបស់រដ្ឋអាជ្ញា សុំឱ្យកត់សម្គាល់តាមផ្លូវតុលាការនូវអង្គហេតុដែលត្រូវបានទទួលយក និងសុំឱ្យទទួលយកសេចក្តីថ្លែងការណ៍ជាលាយល័ក្ខអក្សរ អនុលោមតាមវិធាន ៩២ ស្ទួន ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៣ កថាខណ្ឌ ១១, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Karemera *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-98-44-AR73(C) សេចក្តីសម្រេចបន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អរបស់រដ្ឋអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចលើការកត់សម្គាល់តាមផ្លូវតុលាការ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦ ("សេចក្តីសម្រេចក្នុងរឿងក្តី *Karemera*") កថាខណ្ឌ ៣៩, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Perisic សំណុំរឿងលេខ IT-04-81-PT សេចក្តីសម្រេចលើសំណើសុំឱ្យកត់សម្គាល់តាមផ្លូវតុលាការនូវសេចក្តីប្រកាសពីពិរុទ្ធភាព ដែលបានធ្វើឡើងនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ("សេចក្តីសម្រេចក្នុងរឿងក្តី *Perisic*") កថាខណ្ឌ ៧។

ជាដើម")[45]។ នៅពេលដែលការកត់សម្គាល់នូវព្រឹត្តិការណ៍ទាំងអស់នេះ ត្រូវបានរៀបចំតាមផ្លូវតុលាការ ព្រឹត្តិការណ៍ទាំងអស់នោះ ត្រូវបានគេចាត់ទុកថាត្រូវបានលាតត្រដាង ដោយមិនអាចប្រកែកបាន[46]។

៥០. ក្នុងករណីទីពីរ វាជាអង្គហេតុដែលត្រូវបានរកឃើញក្នុងរឿងក្តីមួយផ្សេងទៀតរបស់តតិយជន[47]។ ដូច្នេះ ការកត់សម្គាល់តាមផ្លូវតុលាការលើអង្គហេតុទាំងអស់នេះ មានឥទ្ធិពលទាញផ្នែកអយ្យការចេញពីបន្ទុកដើមរបស់ខ្លួន ក្នុងការបង្ហាញភស្តុតាង លើចំណុចដែលត្រូវពិចារណា។ អង្គហេតុដែលត្រូវបានរកឃើញ គឺជាការសន្មតងាយៗ ដែលក្រុមមេធាវីការពារក្តី អាចជំទាស់បានតាមរយៈភស្តុតាងក្នុងសំណុំរឿង[48]។

៥១. យោងតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍ របស់តុលាការពិសេស៖

> *"ការយល់ឃើញនេះ ត្រូវគ្នាជាមួយនឹងការអនុវត្តជាធរមាននៅតាមតុលាការជាតិ៖ ការកត់សម្គាល់អង្គហេតុ ដែលបានដឹងឮជាសាធារណៈ អាចត្រូវបានចាត់ទុកជាការកត់សម្គាល់ស្ថាពរ ចំណែកឯការទទួលយកជាស្ថាពរនូវអង្គហេតុណាមួយ ដោយចៅក្រមជំនុំជម្រះក្នុងរឿងក្តីមួយ គឺមានអំណាចចាប់បង្ខំមិនអាចប្រកែកបាន តែសម្រាប់ភាគីទាំងអស់នៃរឿងក្តីតែប៉ុណ្ណោះ"*[49]។

៥២. គេអាចនិយាយបានមួយបែបទៀតថា ដោយអនុលោមតាមគោលការណ៍អាជ្ញាអស់ជំនុំ ការទទួលយកជាស្ថាពរនូវអង្គហេតុណាមួយ ក្នុងរឿងក្តីទីមួយ មានអំណាចចាប់បង្ខំ មិនអាចបដិសេធបានចំពោះភាគីទាំងអស់ក្នុងរឿងក្តីទីពីរ។

---

[45] សេចក្តីសម្រេចក្នុងរឿងក្តី *Karemera* កថាខណ្ឌ ២២, សេចក្តីសម្រេចក្នុងរឿងក្តី *Perisic* កថាខណ្ឌ ៨ ដល់កថាខណ្ឌ ៩។

[46] សេចក្តីសម្រេចក្នុងរឿងក្តី *Karemera* កថាខណ្ឌ ៤២, សេចក្តីសម្រេចក្នុងរឿងក្តី *Perisic* កថាខណ្ឌ ៨។

[47] សេចក្តីសម្រេចក្នុងរឿងក្តី *Karemera* កថាខណ្ឌ ៤០, សេចក្តីសម្រេចក្នុងរឿងក្តី *Perisic* កថាខណ្ឌ ១២។

[48] សេចក្តីសម្រេចក្នុងរឿងក្តី *Karemera* កថាខណ្ឌ ៤២, សេចក្តីសម្រេចក្នុងរឿងក្តី *Perisic* កថាខណ្ឌ ១២។

[49] សេចក្តីសម្រេចក្នុងរឿងក្តី *Karemera* កថាខណ្ឌ ៤២, សេចក្តីសម្រេចក្នុងរឿងក្តី *Perisic* កថាខណ្ឌ ១៨។

៥៣. ទោះបីជា អ.វ.ត.ក មិនបានត្រៀមទុកនូវយន្តការនៃការកត់សម្គាល់តាមផ្លូវតុលាការក៏ដោយ ក៏នៅមានគោលការណ៍អាជ្ញាអស់ជំនុំ ដែលជាវិធាន និងជាយុត្តិសាស្ត្រ[50]។ ប្រសិនបើពុំមានយន្តការនេះទេ គឺមានតែសេចក្តីសម្រេចស្ថាពរប៉ុណ្ណោះ ដែលមានអំណាចចាប់បង្ខំចំពោះភាគីទាំងអស់ក្នុងរឿងក្តីទីពីរ។

៥៤. ផ្ទុយទៅវិញ ដរាបណាអង្គហេតុទាំងអស់ដែលត្រូវបានជំនុំជម្រះក្នុងសំណុំរឿងទីមួយ ហើយដែលអង្គហេតុទាំងនោះមានទំនាក់ទំនង ឬប្រើប្រាស់ជា"មូលដ្ឋាន"ក្នុងការជំនុំជម្រះសំណុំរឿងទីពីរ មិនត្រូវបានទទួលយកជាស្ថាពរនោះទេ អង្គហេតុទាំងនោះនឹងមិនអាចត្រូវបានចាត់ទុកថាត្រូវបានទទួលយកក្នុងសំណុំរឿង ០០២/០២ នោះឡើយ។

## ២. គោលការណ៍អាជ្ញាអស់ជំនុំ និងវិសាលភាពជាក់លាក់នៃសំណុំរឿង ០០២/០១

៥៥. ក្រុមមេធាវីការពារក្តី ទទូចលើការណ៍ដែលខ្លួននៅតែមិនទាន់បានដឹងពីវិសាលភាពពិតប្រាកដ និងជាក់ស្តែងនៃសំណុំរឿង ០០២/០១។ ក្រុមមេធាវីការពារក្តីបានលើកឡើងពីបញ្ហានេះ ក្នុងសំណើសុំបញ្ឈប់ដំណើរការនីតិវិធី[51]។ អង្គជំនុំជម្រះតុលាការកំពូល ដែលយល់ឃើញថា សំណើនេះធ្វើឡើងមុនពេលវេលា បានរំឭកថាក្រុមមេធាវីការពារក្តីអាចលើកការរិះគន់នេះឡើងវិញ នៅពេលធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តី[52]។

[50] សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោស) ឯកសារ E51/15 កថាខណ្ឌ ២៧ និងឯកសារយោងក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៦៤ ដល់លេខ ៦៦។

[51] សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ E275/2/1/1 និង ឯកសារបន្ថែម ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ E275/2/1/3។

[52] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបញ្ឈប់កិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ E275/2/1/4 កថាខណ្ឌ ៧។

៥៦. វិសាលភាពនៃសំណុំរឿង ០០២/០១ គឺអាស្រ័យលើវិសាលភាពនៃសំណុំរឿងបន្តបន្ទាប់។ បញ្ហានេះ មានភាពចម្រូងចម្រាសយ៉ាងខ្លាំង ហើយរហូតមកដល់សព្វថ្ងៃនេះ សំណើសុំបំភ្លឺទាំងអស់ដែលភាគីផ្សេងៗបានដាក់ជូនអង្គជំនុំជម្រះ នៅមិនទាន់ទទួលបានចម្លើយច្បាស់លាស់នៅឡើយ[53]។

៥៧. ដូច្នេះ សាលក្រមក្នុងសំណុំរឿង ០០២/០១ ដែលនឹងត្រូវចេញនាពេលខាងមុខ អាចនឹងឲ្យភាគីទាំងអស់បានដឹងពីវិសាលភាពជាក់លាក់ ពិតប្រាកដ និងជាក់ស្តែង នៃសំណុំរឿងនេះបាន។ ក្នុងករណីមានបណ្តឹងសាទុក្ខ (ដែលប្រាកដជានឹងមានភាគច្រើន) គឺត្រូវតែរង់ចាំសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីឲ្យវិសាលភាពពិតប្រាកដនៃសំណុំរឿងទីមួយ ត្រូវបានជំនុំជម្រះ និងលាតត្រដាងជាស្ថាពរ។ ផ្អែកតាមមូលហេតុទាំងអស់នេះ ក្រុមមេធាវីការពារក្តី សូមបញ្ជាក់ថា ការជំនុំជម្រះសំណុំរឿង ០០២/០២ មិនអាចចាប់ផ្តើមបាន មុននឹងការប្តឹងសាទុក្ខទាំងអស់ត្រូវបានបញ្ចប់នោះទេ។

៥៨. លើសពីនេះទៅទៀត ការជំនុំជម្រះសំណុំរឿង ០០២/០២ មិនត្រូវចាប់ផ្តើមបានឡើយ ដរាបណាអង្គជំនុំជម្រះតុលាការកំពូល មិនទាន់បានសម្រេចលើគ្រប់សេចក្តីសម្រេចទាំងអស់ដែលអាចនឹងមានការប្តឹងសាទុក្ខ ក្នុងពេលជាមួយគ្នានឹងសាលក្រមលើអង្គសេចក្តី[54]។

## III. ភាពចាំបាច់ក្នុងការរង់ចាំការបញ្ចប់ការប្តឹងសាទុក្ខលើសេចក្តីសម្រេចទាំងអស់ ក្រោយពីសាលក្រមលើអង្គសេចក្តី

[53] ឧទាហរណ៍ សូមមើល សំណើទាំងពីចុងក្រោយសុំការបំភ្លឺ ដែលត្រូវបានដាក់បន្ទាប់ពីការបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី ក្នុងពេលសរសេរសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល៖ សំណើរបស់សហព្រះរាជអាជ្ញា សុំការបំភ្លឺអំពីការរកឃើញទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ដូចបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ E284/5, សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំការបំភ្លឺលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងអញ្ញត្រកម្មនៃការមិនទទួលយកកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ និងរបាយការណ៍នៃចំណុចចាប់ផ្តើមនៃរយៈពេលកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ E299/1។

[54] វិធាន ១០៤ (៤) នៃវិធានផ្ទៃក្នុង។

៥៩. ត្រង់ចំណុចនេះ ក្រុមមេធាវីការពារក្ដី មានការសោកស្ដាយ ដោយសារិធានផ្ទៃក្នុង បានកម្រិតការធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាន់បន្ទំ។ ចំពោះសំណុំរឿងទីពីរ ដែលនឹងត្រូវជំនុំជម្រះដោយចៅក្រមដដែល ដែលបានដឹកនាំការជំនុំជម្រះសំណុំរឿងទីមួយ វាពិតជាចាំបាច់ណាស់ក្នុងការរង់ចាំឲ្យអង្គជំនុំជម្រះតុលាការកំពូល សម្រេចលើរាល់សេចក្ដីសម្រេចទាំងអស់ ដែលអង្គជំនុំជម្រះសាលាដំបូងបានចេញក្នុងសំណុំរឿង ០០២/០១ ហើយដែលសេចក្ដីសម្រេចទាំងអស់នោះ នឹងក្លាយជាកម្មវត្ថុនៃការប្ដឹងឧទ្ធរណ៍ក្នុងពេលតែមួយជាមួយនឹងសាលក្រមលើអង្គសេចក្ដី។

៦០. មូលហេតុគឺថា សេចក្ដីសម្រេចទាំងអស់នោះ ពាក់ព័ន្ធជាពិសេសនឹងភាពទទួលយកបាន និងការបង្ហាញភ័ស្ដុតាង ហើយនឹងមានផលវិបាកធំធេងលើការប្រព្រឹត្តទៅ និងការរៀបចំសំណុំរឿងវគ្គទី ២។

៦១. ជំនុំជម្រះសំណុំរឿង ០០២/០២ ក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងសំណុំរឿង ០០២/០១ ដោយមិនរង់ចាំការប្ដឹងសាទុក្ខចប់ ទំនងជានឹងមានផលវិបាកធ្ងន់ធ្ងរលើសំណុំរឿងវគ្គទី ២ ហើយទំនងជាអាចក្លាយជា *"ឧបសគ្គក្នុងការអនុវត្តប្រកបដោយប្រសិទ្ធិភាព និងជាក់ស្ដែង នូវសិទ្ធិប្ដឹងឧទ្ធរណ៍"* ហើយជាមួយគ្នានេះដែរ វាក៏អាចប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ *"ក្នុងការមានពេលវេលា និងមធ្យោបាយចាំបាច់សម្រាប់រៀបចំការការពារខ្លួន"*។ វាក៏ទំនងជា *"ផ្ទុយនឹងប្រសិទ្ធិផលនៃមធ្យោបាយតុលាការ"* ផងដែរ។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា *"ភាពច្បាស់លាស់ផ្នែកគតិយុត្ត"* ត្រូវតែបាន *"ធានាចំពោះគ្រប់ភាគីទាំងអស់"* ហើយនិតិវិធីទាំងឡាយត្រូវតែធ្វើឡើង *"ក្នុងរយៈពេលកំណត់ជាអប្បបរមា និងមានប្រសិទ្ធិភាពជាអតិបរមា"* [55]។

៦២. ក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន ទទួចថា ភាពច្បាស់លាស់អាចបង្កើននូវប្រសិទ្ធិភាព និងកាត់បន្ថយរយៈពេលកំណត់។ ហេតុដូច្នេះហើយ ប្រយោជន៍យុត្តិធម៌ និងការរៀបចំការជំនុំជម្រះមួយដែលយុត្តិធម៌ តម្រូវឲ្យរងចាំអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូលជាមុនសិន។

---

[55] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E284/2/1/2 កថាខណ្ឌ ៦។

## IV. បញ្ហានិន្នផលរយៈពេលកំណត់នៃនីតិវិធីប្តឹងសាទុក្ខ

៦៣. ក្រុមមេធាវីការពារក្តី សូមឯកភាពជាមួយលោកស្រីចៅក្រម CARTWRIGHT ដែលថាយើងត្រូវ *"ប្រឈមនឹងការពិត"* និង *"យកចិត្តទុកដាក់លើពេលវេលាចាំបាច់សម្រាប់អង្គជំនុំជម្រះតុលាការកំពូល"* ក្នុងការធ្វើអន្តរាគមន៍[56]។ ក្រុមមេធាវីការពារក្តី បានដឹងយ៉ាងច្បាស់ពីរយៈពេលកំណត់ចន្លោះរវាងសាលក្រម និងសាលដីកាក្នុងសំណុំរឿង ០០១ (១៨ ខែ)។ ជាមួយគ្នានេះដែរ ក្រុមមេធាវីការពារក្តី មានការសោកស្តាយចំពោះពេលវេលា ក្នុងសំណុំរឿង ០០២/០១ នោះគឺចន្លោះពេលដាក់បណ្តឹងឧទ្ធរណ៍ផ្សេងៗ ប្រឆាំងនឹងសេចក្តីសម្រេចថ្មីលើការបំបែកកិច្ចដំណើរការនីតិវិធី និងការចេញសេចក្តីសម្រេចមួយដែលមានសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្តឹងឧទ្ធរណ៍ទាំងអស់នេះ (៦ ខែ)។

៦៤. ការពិចារណាទាំងអស់នេះ មិនអាចក្លាយជាមូលហេតុនៃការសម្រេចចាប់ផ្តើមសំណុំរឿង ០០២/០២ មុននឹងមានអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០២/០១ បានឡើយ។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង បានរំឮកពាក់ព័ន្ធនឹងមូលហេតុនៃការរក្សាឃុំខ្លួនជនជាប់ចោទមួយរូប ក្នុងសំណុំរឿងស្មុគស្មាញ ថាការដកហូតសេរីភាពអាចស្របច្បាប់ *"ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ច បានផ្តល់នូវការយកចិត្តទុកដាក់ជាពិសេសក្នុងការបន្តកិច្ចដំណើរការនីតិវិធី"*។ ឧទាហរណ៍ មានកត្តាមួយចំនួនទៀត ដែលត្រូវយកមកពិចារណានោះគឺ *"វិធីសាស្ត្រដែលគេរៀបចំប្រព័ន្ធតុលាការ និងថាតើអាជ្ញាធរមូលដ្ឋាន បានចាត់ចែងធនធានបន្ថែម ឬបង្កើតអង្គភាពពិសេសមួយឬទេ ពាក់ព័ន្ធនឹងបញ្ហានេះ"*[57]។

៦៥. ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន មានភាពប្រាកដនិយមណាស់ និងបានដឹងពីរយៈពេលកំណត់ដែលមិនអាចបង្រួញបាន សម្រាប់ការពិភាក្សាសម្រេច និងការសរសេរសេចក្តីសម្រេច

[56] ប្រតិចារឹកសវនាការ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ E1/238.2 ទំព័រ ៧៧ បន្ទាត់ ៦ ម៉ោងប្រហែល [១១.៤៦.២៨] [ប្រតិចារឹកជាភាសាបារាំង]។

[57] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសំណើសុំដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ E275/2/3 កថាខណ្ឌ ៥០។

(ជាមូលហេតុដែលក្រុមមេធាវីការពារក្តី បានប៉ាន់ប្រមាណផងដែរថា អង្គជំនុំជម្រះសាលាដំបូង មិនអាចសរសេរសាលក្រមសម្រាប់សំណុំរឿង ០០២/០១ ក្នុងរយៈពេល ៦ ខែ ដោយត្រូវដឹកនាំធ្វើសវនាការក្នុងសំណុំរឿង ០០២/០២ ទន្ទឹមគ្នាបានឡើយ)។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តី យល់ឃើញថា រយៈពេលកំណត់អន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០២/០១ អាចនឹងត្រូវកាត់បន្ថយ ហើយអង្គជំនុំជម្រះតុលាការកំពូល អាចនឹងចាប់ផ្តើមរៀបចំខ្លួន ចាប់ពីពេលនេះទៅ ដោយបង្គាប់ឲ្យផ្នែករដ្ឋបាល ធ្វើការជ្រើសរើសបុគ្គលិក ពីពេលឥឡូវនេះទៅ។ មូលហេតុ គឺថា៖

> *"ដោយដឹងថាអាយុកាន់តែចាស់ និងសុខភាពរបស់ជនជាប់ចោទកាន់តែធ្លាក់ចុះ ក៏ដូចជាភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដែលមានសេសសល់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចនេះ ជាការតម្រូវថា អ.វ.ត.ក ដំណើរការជារៀងរាល់ថ្ងៃ ដែលខ្លួនអាចធ្វើទៅបាន ដើម្បីធានានូវការសម្រេចជាស្ថាពរលើបទចោទ ដែលសេសសល់ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន"*[58]។

៦៦. ទោះបីជាលោក ខៀវ សំផន ជាអ្នកទីមួយដែលបានទាមទារឲ្យមានការជំនុំជម្រះឲ្យបានឆាប់រហ័សក៏ដោយ ក៏លោកបានយល់ឃើញថា អនុលោមតាមសិទ្ធិរបស់លោកក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសច្ចភាពគតិយុត្ត គេត្រូវសម្រេចជាស្ថាពរលើរូបលោកក្នុងសំណុំរឿង ០០២/០១ ជាមុនសិន មុននឹងចាប់ផ្តើមសំណុំរឿង ០០២/០២។

៦៧. **អាស្រ័យហេតុនេះ** ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង មេត្តា៖

- **ប្រកាស** និង **វិនិច្ឆ័យថា** សំណុំរឿង ០០២/០២ នឹងមិនអាចចាប់ផ្តើមបានឡើយ មុនពេលដែលសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ។

---

[58] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E163/5/1/13 កថាខណ្ឌ ៥១។

– **ប្រកាស** និង **វិនិច្ឆ័យថា** សំណុំរឿង ០០២/០២ នឹងមិនអាចចាប់ផ្ដើមបានឡើយ មុនពេលដែលអង្គជំនុំជម្រះតុលាការកំពូល មិនទាន់បានសម្រេចលើរាល់សេចក្ដីសម្រេចទាំងឡាយ ដែលអាចនឹងមានការប្ដឹងសាទុក្ខ ក្នុងពេលជាមួយគ្នានឹងសាលក្រមលើអង្គសេចក្ដី ក្នុងសំណុំរឿង ០០២/០១។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស | |